សេចក្តីថ្លែងការណ៍រួម

# ស្នើសុំដោះលែង និងទម្លាក់ចោលបទចោទ
# លើអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនការពារបរិស្ថាន
# លោក កើត សារ៉ាយ

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤

ក្រុមយុវជន សហគមន៍មូលដ្ឋាន សហជីព សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ មានការសោកស្តាយជាខ្លាំងចំពោះការចាប់ឃុំខ្លួនលោក កើត សារ៉ាយ ប្រធានសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ (KSILA) និងជាអ្នកការពារសិទ្ធិមនុស្សដ៏សកម្មមួយរូប។

សូមបញ្ជាក់ថាលោក កើត សារ៉ាយ ត្រូវបានមន្រ្តីនគរបាលរាជធានីភ្នំពេញចូលចាប់ខ្លួន ខណៈលោក កំពុងបំពេញការងារនៅការិយាល័យ រួចបញ្ជូនទៅកាន់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញវេលា ម៉ោង១៥.៤៥នាទី កាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤ តាមដីកាបញ្ជាឱ្យចូលខ្លួនរបស់លោក សេង ហៀង ព្រះរាជអាជ្ញារងនៃ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៤ ដែលក្នុងដីកានោះបានត្រឹមបញ្ជាក់ ថាពាក់ព័ន្ធករណី **ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម**។ ការចាប់ខ្លួននេះធ្វើឡើងដោយមិន បានផ្តល់ព័ត៌មានជាក់លាក់ អំពីបទចោទប្រកាន់ទៅកាន់លោកកើត សារ៉ាយ និងក្រុមគ្រួសាររបស់ លោកឡើយ។ យោងតាមសេចក្តីប្រកាសព័ត៌មានរបស់អយ្យការអមសារដំបូងរាជធានីភ្នំពេញ បានប្រកាសថាលោក កើត សារ៉ាយក៏បានប្រឈមនឹងការចោទប្រកាន់បន្ថែមពីបទ **មិនរាងចាលក្នុងបទមជ្ឈឹមបន្ទាប់ពីផ្តន្ទាទោសបទមជ្ឈឹម** ព្រមទាំងបានឃុំខ្លួនជាបណ្តោះអាសន្ននៅពន្ធនាគារព្រៃសនៅរសៀលថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៤។

ការឃាត់ខ្លួន និងឃុំខ្លួន លោកកើត សារ៉ាយ  គឺជាការបន្តបិទសំឡេង និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងបង្ក្រាបទៅលើសកម្មជនសិទ្ធិមនុស្ស និងបរិស្ថាន ដែលនេះជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិសេរីភាព ជាមូលដ្ឋានដែលធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា។ ការផ្តល់បទសម្ភាសន៍ដល់សារព័ត៌មាន ជាពិសេសការបញ្ចេញមតិពីវិវាទដីធ្លីក្នុងខេត្តព្រះវិហារ គឺជាការខ្វាយខ្វល់ចំពោះបញ្ហាជីវភាពរបស់ពលរដ្ឋ និងពាំនាំក្តីកង្វល់របស់ពួកគេដើម្បីជំរុញឱ្យអាជ្ញាធរដោះស្រាយបញ្ហាដល់ពលរដ្ឋប៉ុណ្ណោះ។ ការបញ្ចេញមតិរបស់លោកគួរត្រូវបានចាត់ទុកថាជាការជួយដល់អាជ្ញាធរក្នុងការដោះស្រាយបញ្ហាជាជាងការញុះញង់។ បន្ថែមលើសពីនេះការចាប់ខ្លួនសកម្មជននៅកៀកថ្ងៃនៃការប្រារព្ធ ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ គឺរឹតតែធ្វើឱ្យលោកបាត់បង់នូវសិទ្ធិសេរីភាពជួបជុំសមាជិកក្រុមគ្រួសារអំឡុង ពេលបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរនេះ ដែលពលរដ្ឋខ្មែរគ្រប់រូបចាត់ទុកថាជាឱកាសដ៏វិសេសវិសាលក្នុងការ ជួបជុំគ្រួសារផងដែរ។

សូមរំលឹកថាកាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២០ លោក កើត សារ៉ាយ ដែលជាអតីតព្រះសង្ឃក៏ធ្លាប់ត្រូវបានអាជ្ញាធរចាប់ព្រះកាយហើយផ្សឹក នៅពេលធ្វើការតស៊ូមតិស្នើសុំឱ្យដោះលែងថ្នាក់ដឹកនាំសហជីពលោករ៉ុង ឈុន។

សារ៉ាយ ត្រូវបានកាត់ទោសរួមជាមួយយុវជនជាអតីតសកម្មជនសង្គមចំនួន១៣នាក់ផ្សេងទៀតដោយសារ គ្រានោះលោកត្រូវបានតុលាការរាជធានី ភ្នំពេញចោទប្រកាន់ពីបទញុះញង់តាមបញ្ញត្តិមាត្រា៤៩៤ និងមាត្រា៤៩៥នៃក្រមព្រហ្មទណ្ឌ។ លោកត្រូវបានតុលាការកាត់ទោសឱ្យជាប់ ពន្ធនាគារ២០ខែ ប៉ុន្តែបន្ទាប់ពីអនុវត្តទោសបានមួយឆ្នាំបួនខែ ទោសនេះក៏ត្រូវបានព្យួររយៈពេល៦ខែ។ លោកត្រូវបានដោះលែងឱ្យមានសេរីភាពឡើងវិញនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១។ ការផ្តន្ទាទោសលោក សារ៉ាយ និងសកម្មជនយុវជន ៨ នាក់ផ្សេងទៀត ត្រូវបានតុលាការកំពូលតម្កល់កាលពីខែឧសភា ឆ្នាំ ២០២៣។

យើងទាំងអស់គ្នាជាក្រុមយុវជន សហគមន៍ សហជីព សមាគម អង្គការសង្គមស៊ីវិលជាតិសូមអំពាវនាវដល់សាលាដំបូងរាជធានីភ្នំពេញមេត្តាទម្លាក់ចោលបទចោទ និងដោះលែងសកម្មជនសិទ្ធិមនុស្ស និងបរិស្ថានលោកកើតសារ៉ាយជាបន្ទាន់និងឥតលក្ខខណ្ឌ និងបើកចំហសេរីភាពក្នុងការបញ្ចេញមតិ ឱ្យបានពេញលេញដល់ពលរដ្ឋ ដែលខ្វល់ខ្វាយ ពីបញ្ហាសង្គម។ យើងខ្ញុំទាំងអស់គ្នាសូមអំពាវនាវដល់អាជ្ញាធររដ្ឋ មេត្តាគោរពនិងបើកចំហលំហសេរីភាពអង្គការ សមាគមគោរពសិទ្ធិមនុស្ស គោរពសិទ្ធិអ្នកការពារសិទ្ធិមនុស្ស និងលើកកម្ពស់សេរីភាពបញ្ចេញមតិដើម្បីចូលរួម ស្ថាបនាប្រទេសជាតិ៕

សេចក្តីថ្លែងការណ៍នេះគាំទ្រដោយៈ

| | | |
|---|---|---|
| 1. | សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ | KSILA |
| 2. | សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ | IDEA |
| 3. | អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ | PED |
| 4. | សមាគមបណ្តាញយុវជនកម្ពុជា | CYN |
| 5. | សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ | LICADHO |
| 6. | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា | ADHOC |
| 7. | មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស | CENTRAL |
| 8. | សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្ម កម្ពុជា | CFSWF |
| 9. | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា | COMFREL |
| 10. | សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ | LRSU |
| 11. | សហព័ន្ធសហជីពកម្មករនយោជិតវិស័យទេសចរណ៍កម្ពុជា | CTWUF |
| 12. | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព | PDP-Center |
| 13. | អង្គការអភិវឌ្ឍន៍ធនធានយុវជន | YRDP |
| 14. | អង្គការសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម | CISA |
| 15. | វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា | CID |
| 16. | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | CCHR |
| 17. | សម្ព័ន្ធសហជីពកម្ពុជា | CATU |
| 18. | សហព័ន្ធសហជីពសេរីឯករាជ្យ | FUFI |

| | |
|---|---|
| 19. អង្គការអប់រំយុវជនដើម្បីអភិវឌ្ឍន៍ និងសន្តិភាព | YEDP |
| 20. សមាគមន៍កម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ | CIWA |
| 21. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា<br>ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ | NGO-CEDAW |
| 22. សហព័ន្ធសហជីពឯករាជ្យ | INTUFE |
| 23. សហពន្ធ័សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា | FTUWKC |
| 24. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា | GADC |
| 25. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា | CHRAC |
| 26. អង្គការសមាគមធាងត្នោត | STT |
| 27. ចលនាមាតាធម្មជាតិ | |
| 28. សហគមន៍ព្រៃឡង់ (ខេត្តស្ទឹងត្រែង) | |
| 29. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង) | |
| 30. សហគមន៍ព្រៃឈើត្រពាំងចាន់ (កំពង់ឆ្នាំង) | |
| 31. សហគមន៍ព្រៃឡង់ (ព្រះវិហារ) | |
| 32. សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ) | |
| 33. សហគមន៍រស្មីសាមគ្គី (កំពង់ស្ពឺ) | |
| 34. សហគមន៍អមលាំង (កំពង់ស្ពឺ) | |
| 35. សហគមន៍ដីធ្លី ១៩៧ (កោះកុង) | |
| 36. សហគមន៍ដីធ្លីជីខក្រោម (កោះកុង) | |
| 37. សហគមន៍ព្រៃឈើពេជ្រចង្វាល្អឆើត (កំពង់ឆ្នាំង) | |
| 38. សហគមន៍ដីធ្លីស្រែប្រាំង (ត្បូងឃ្មុំ) | |
| 39. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់) | |
| 40. សហគមន៍ភ្នំក្រោម (សៀមរាប) | |
| 41. សហគមន៍ដីធ្លីតានី (សៀមរាប) | |
| 42. សហគមន៍ដីធ្លីខេត្តប៉ៃលិន | |
| 43. សហគមន៍បឹងប្រាំ (បាត់ដំបង) | |
| 44. សហគមន៍ដីធ្លីអណ្តូងត្របែក (ស្វាយរៀង) | |
| 45. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង) | |
| 46. សហគមន៍ព្រៃឡង់ (ក្រចេះ) | |
| 47. សហគមន៍ព្រៃឡង់ (កំពង់ធំ) | |
| 48. សហគមន៍ត្នោតជុំ (ពោធិ៍សាត់) | |
| 49. សហគមន៍ជនជាតិដើមភាគតិចកួយ ខេត្តព្រះវិហារ | |
| 50. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ) | |

51. សហគមន៍ ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)
52. សហគមន៍សាមគ្គីរមាសហែក (ស្វាយរៀង)
53. សហគមន៍សង្កែពីរមានរិទ្ធិ (ព្រះវិហារ)
54. សហគមន៍សំរោងត្បូង (ភ្នំពេញ)
55. សហគមន៍ទន្លូង (ត្បូងឃ្មុំ)
56. សហគមន៍មានជ័យ (ស្វាយរៀង)